# ១១

## អំពី សិស្ស ពូកែ ជាងគ្រូ

*សិស្សពូកែជាងគ្រូ មិនមានអ្វីប្លែកទេ បើគ្រូជាមនុស្សសាមញ្ញធម្មតា តែបើគ្រូជាព្រះពុទ្ធ* **គោតម** *សូមមើលឲ្យគ្រប់ជ្រុងជ្រោយផង មើលឲ្យអស់ ៨៤០០០ ធម្មក្ខន្ធ ជាមុនសិន មុននឹងនិយាយថា ធម៌ព្រះពុទ្ធ ខ្វះត្រង់នេះ ឬ ខ្វះត្រង់នោះ ។ មានពេលមួយ ព្រះពុទ្ធព្រមទាំងបរិវារ បានមកដល់ព្រៃឈើ ហើយសម្រាកក្រោមដើមឈើមួយដើម ។ ព្រះអង្គបានយកស្លឹកឈើមួយក្ដាប់ មកសួរភិក្ខុទាំងឡាយថា « ម្នាលភិក្ខុទាំងឡាយ ស្លឹកឈើនៅក្នុងបាតដៃតថាគត និង ស្លឹកឈើនៅក្នុងព្រៃនេះ តើស្លឹកឈើណាច្រើនជាង »។ ព្រះភិក្ខុឆ្លើយថា គឺ ស្លឹកឈើនៅក្នុងព្រៃ ។ ព្រះអង្គមានព្រះបន្ទូលតទៅទៀតថា « ធម៌ដែលតថាគតត្រាស់ដឹង ប្រៀបដូចស្លឹកឈើនៅក្នុងព្រៃនេះ តែធម៌ដែលតថាគតយកមកផ្សព្វផ្សាយប្រៀបដូចស្លឹកឈើនៅក្នុងបាតដៃតថាគត ពីព្រោះតថាគតយកតែធម៌ណាដែលមានប្រយោជន៍ដល់សព្វសត្វ » ។*

*បើយោងទៅតាមពុទ្ធដីកានេះ ធម៌ដែលព្រះអង្គយកមកបង្ហាត់បង្រៀនទាំងប៉ុន្មានសុទ្ធតែមានប្រយោជន៍ដល់យើងទាំងអស់ ដូចជា ការធ្វើសមាធិ ជាដើម ។ ចុះហេតុអ្វី បានជាមានលោកគ្រូ* **អភិធម្ម** *មួយក្រុមបានពន្យល់សិស្សថា ៖ « ឲ្យតែយល់ធម៌អភិធម្ម ទៅមិនចាំបាច់ ធ្វើការបដិបត្តិអ្វីទៀតទេ ពីព្រោះការបដិបត្តិនៅនឹងការយល់នេះហើយ » ។ ហើយលោកបានបញ្ជាក់ថែមទៀតថា ៖*

*« ធ្វើសមាធិ នាំតែឲ្យខាតពេល » ។*

*ចំពោះការអះអាង របស់លោកគ្រូអភិធម្មទាំងនោះ ខ្ញុំសូមលើកយករឿង ដែលមានក្នុង*

គម្ពីរ ជាតកសុត្តាង បន្ទាប់មកខ្ញុំសូមលើកជាសំណួរ ជូនទៅឲ្យលោកគ្រូទាំងនោះ[1] ៖

មានថ្ងៃមួយ នៅតាមផ្លូវ ដល់វេលាយប់ ព្រះពុទ្ធទ្រង់សំណាក់នៅរានហាលមុខផ្ទះអ្នកស្មូនឆ្នាំងម្នាក់។ នៅមុនពេលនោះ ក៏មានយុវជន ជាអ្នកបួសម្នាក់ ឈ្មោះ បុក្កុសាតិ បានមកសុំសំណាក់នៅទីនោះដែរ ។ ព្រះពុទ្ធដោយឃើញយុវជននោះមានឫកពាសមរម្យ ក៏សួរទៅយុវជននោះថា តើអ្នកចេញចាកគ្រួសារ មកបួស តាមគ្រូណា ? តាមទ្រឹស្តីណា ? បុក្កុសាតិ ឆ្លើយថា ខ្ញុំបួសតាម ព្រះគោតម ដែលមានឈ្មោះល្បីថាជាព្រះអរហន្ត បានត្រាស់ដឹងដ៏បរិបូរ ។

- ព្រះអង្គសួរតទៅទៀតថា : តើព្រះអរហន្តនោះ គង់នៅឯណា ?
- ព្រះអង្គគង់នៅក្រុងសាវត្ថី ភាគប្រទេសខាងជើង
- តើអ្នកឯង ដែលបានឃើញទេ ហើយស្គាល់ទេ ប្រសិនបើជាបានជួប
- ខ្ញុំពុំដែលបានឃើញទេ ហើយក៏ពុំស្គាល់ដែរ ប្រសិនបើជាខ្ញុំបានជួបព្រះអង្គ ។

ព្រះពុទ្ធ ទ្រង់ជ្រាបថា គឺក្នុងនាមព្រះអង្គហើយ ដែលអ្នកបួសនេះចេញចាកគ្រួសារ ហើយក៏ទ្រង់មានព្រះបន្ទូលតទៅទៀតថា ៖ ម្នាលភិក្ខុ ចូរអ្នកប្រុងស្តាប់ទ្រឹស្តីដូចតទៅនេះ យើងនឹងសម្តែង ៖

- ប្រសើរណាស់ អាវុសោ (ភិក្ខុនោះឆ្លើយ) ។

ព្រះអង្គក៏ចាប់សម្តែងដោយពិស្តារអំពី និរោធសច្ច: (ព្រះនិព្វាន) ។ លុះបានស្តាប់ចប់ហើយ ភិក្ខុនោះក៏ដឹងថា អ្នកដែលសម្តែងនេះ គឺជាព្រះពុទ្ធ ហើយក៏ងើបឈរឡើងអោនថ្វាយបង្គំព្រះអង្គចំពីមុខ ហើយសុំខមាទោសពីព្រះអង្គ ដោយបានទុកព្រះអង្គ

[1] បើលោកគ្រូចង់ឆ្លើយ សូមប្រើ អាស័យដ្ឋាន របស់ពេជពុម្ពសៀវភៅនេះ។

ស្មើនឹងខ្លួន ដោយប្រើពាក្យអាវុសោ (មានន័យថា មិត្ត) ។ ហើយក៏សុំឲ្យព្រះអង្គបំបួស ។ ព្រះអង្គទ្រង់មានបន្ទូលថា ដើម្បីនឹងបួស អ្នកត្រូវមាន ត្រៃចីវរ និង បាត្រ ដូច្នេះចូរអ្នកទៅរករបស់នោះមក ។ បុក្កុសាតិ ក៏ចេញទៅរក ត្រៃចីវរ និង បាត្រ តែត្រូវ គោញីរំជស្លាប់ ។ ដល់ពេលក្រោយមក លុះដំណឹងដ៏កំសត់នេះបានទៅដល់ព្រះពុទ្ធ ព្រះអង្គទ្រង់មានបន្ទូលថា បុក្កុសាតិ ជាអ្នកមានបញ្ញា បានយល់អរិយសច្ចៈ នេះជាជាតិចុងក្រោយ របស់គេហើយ។ គេបានសម្រេចអនាគាមី គេមិនត្រឡប់មកកើតទៀតឡើយ ។ ចាប់ពីនេះទៅខ្ញុំសូមលើកជា សំណួរ ដូចតទៅ ៖

១- នៅក្នុង រឿងនេះ បុក្កុសាតិ បានសម្រេច អនាគាមី ដោយគ្រាន់តែយល់ធម៌ អរិយសច្ចៈ មិនចាំបាច់ចេះធម៌ អភិធម្ម ផង។

២- ព្រះពុទ្ធ បន្ទាប់ពីបានត្រាស់ដឹង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតា នៅឋាន តុសិតា ដោយសម្តែង ធម៌អភិធម្ម ធម៌ដែលលោកគ្រូអភិធម្ម យកមកបង្រៀនសព្វថ្ងៃនេះ ។ ហើយតាមដែលយើងបានដឹងថា ពុទ្ធមាតា បន្ទាប់ពីបានយល់ធម៌អភិធម្មសម្តែង ដោយព្រះពុទ្ធផ្ទាល់ផង បានសម្រេចត្រឹមតែ សោតាប៉ុណ្ណោះ។ ដូច្នេះមិនទាន់សម្រេចនិព្វានឯណា ។ បើបានតែត្រឹមសោតា នោះត្រូវកើត ៧ជាតិទៀតយ៉ាងតិចមុននឹងសម្រេចព្រះនិព្វាន ។ ចុះក្នុង ៧ ជាតិចុងក្រោយនេះ មួយថ្ងៃៗ ពុទ្ធមាតាធ្វើអ្វីខ្លះទៅ បើមិនចម្រើន សីល សមាធិ បញ្ញា ដែលជាការបដិបត្តិ ។ ទុកជាព្រះពុទ្ធក៏ព្រះអង្គ ចម្រើន អានាបានស្សតិ រឿយៗខ្លះៗដែរ មុននឹងបរិនិព្វាន ហើយ សាវកព្រះអង្គ ក៏ចំរើនការនោះដែរ មុននឹងបរិនិព្វាន ។

៣- ប្រសិនបើជាសមាធិ ឥតប្រយោជន៍ ម្តេចក៏ព្រះអង្គ មិនលុបសមាធិ នោះចោលទៅ ទុកតែធម៌អភិធម្ម ឲ្យយើងរៀនពល់គ្នាទៅ នោះគ្រប់គ្រាន់ហើយ ។

៤- តាមធម្មតាគ្រូ មុននឹងពន្យល់សិស្ស នូវធម៌អ្វីមួយ ទាល់តែខ្លួនឯងយល់ធម៌នោះ

ជាមុនសិន ទើបសិស្សអាចយល់បាន។ ដោយយោងទៅតាមពាក្យសំដីលោកគ្រូអភិធម្ម ដែលថា « ឲ្យតែយល់ នោះបានសម្រេច មគ្គផលហើយ » តើលោកបានសម្រេចដល់ណាហើយដែរ សព្វថ្ងៃនេះ? អាចប្រាប់ខ្ញុំផងបានទេ ដើម្បី ជាភស្តុតាង។ ភស្តុតាងសំខាន់ណាស់ សម្រាប់ធ្វើឲ្យគេជឿ ដូចព្រះពុទ្ធ ប្រសិនបើជាមានតែព្រះអង្គមួយអង្គឯងដែលបានសម្រេចនិព្វាននោះ ប្រហែលជាមានគេមិនជឿច្រើនជាងសព្វថ្ងៃនេះទៅទៀត តែភស្តុតាង គឺមានសាវកព្រះអង្គជាច្រើនបានសម្រេចនិព្វានដូចព្រះអង្គដែរ ។